ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្មចិញ្ចឹមត្រីអណ្ដែងក្នុងស្រះ




រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**



ខែកុម្ភៈ ឆ្នាំ២០២៤

មាតិកា

១-សេចក្តីផ្តើម.....1
២-ចរិតលក្ខណៈរស់នៅរបស់ត្រីអណ្តែង.....1
៣-បច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្រះ.....2
៣.១. ការជ្រើសរើសទីតាំងជីកស្រះ.....2
៣.២. ការរៀបចំស្រះ.....2
៣.៣. ការដាក់កូនត្រីពូជ.....2
៣.៤. ការផ្តល់ចំណី.....3
៣.៥. ការគ្រប់គ្រង និងការថែទាំ.....4
៣.៦. ការប្រមូលផល.....5
៤-គម្រោងអាជីវកម្មចិញ្ចឹមត្រីអណ្តែងក្នុងស្រះ.....6
៤-១- គម្រោងចិញ្ចឹម.....6
៤-២- ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង.....7
៤-៣- ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹម១វគ្គ.....7
៤-៤- ការវិភាគលទ្ធផលដោយផ្អែកលើអត្រាបាត់បង់ និងតម្លៃលក់.....9
៤-៥- ខ្សែប្រវាក់តម្លៃ.....9
៥-ហានិភ័យ និងបញ្ហាប្រឈម.....10
៦-សេចក្តីសន្និដ្ឋាន.....11
ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ.....11

## ១-សេចក្តីផ្តើម

ត្រីអណ្តែងជាប្រភេទត្រីងាយស្រួលក្នុងការចិញ្ចឹម ដែលអាចចិញ្ចឹមជាលក្ខណៈគ្រួសារតាមបែបពាក់កណ្តាលប្រពលវប្បកម្ម និងប្រពលវប្បកម្មនៅក្នុងអាង តង់ប្លាស្ទិក ស្រះ បែរ និងចិញ្ចឹមតាមប្រព័ន្ធបាយអូប្លុក (Biofloc System Technology) ដែលមានលក្ខណៈបច្ចេកទេសទំនើប។

ដើម្បីរួមចំណែកជួយអភិវឌ្ឍន៍លើអាជីវកម្មចិញ្ចឹមត្រីអណ្តែង បង្កើនផលិតភាព និងប្រាក់ចំណូលដល់កសិករ ក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម “**អេ.អ.ឌី.ប៊ី**” បានធ្វើការសិក្សា និងរៀបចំឡើងនូវ “**គម្រោងអាជីវកម្មចិញ្ចឹមត្រីអណ្តែងក្នុងស្រះ**” ទុកជាឯកសារជំនួយស្មារតី ឬជាមូលដ្ឋានគ្រឹះដល់ប្រជាកសិករ ក្នុងការចាប់ផ្តើមអាជីវកម្មដំបូង ឬកែសម្រួលច្រវាក់ផលិតកម្មរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។

ក្រៅពីណែនាំលើបច្ចេកទេសក្នុងការចិញ្ចឹម ឯកសារនេះក៏មានការវិភាគនូវគម្រោងផែនការអាជីវកម្មដំបូង ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹមត្រីក្នុង១វគ្គ ការវិភាគខ្សែច្រវាក់តម្លៃ និងការគ្រប់គ្រងហានិភ័យលើផលិតកម្ម ដែលមានលក្ខណៈងាយស្រួលក្នុងការអនុវត្ត បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់កសិករផងដែរ។

## ២-ចរិតលក្ខណៈរស់នៅរបស់ត្រីអណ្តែង

ត្រីអណ្តែងជាត្រីគ្មានស្រកា សម្បុរជាតិរំអិល មានសារធាតុចិញ្ចឹមច្រើន មានដងខ្លួនរាងស្តើងនៅចុងកន្ទុយ ក្បាលរាងសំប៉ែត និងមានប្រវែងវែងបំផុត ៤៧សង់ទីម៉ែត្រ។ អណ្តែងជាប្រភេទត្រីក្នុងស្រុក រស់នៅតំបន់ទឹកសាប ទន្លេ ស្ទឹង ត្រពាំង បឹង ប្រឡាយ ស្រះ និងនៅតាមវាលស្រែជាដើម។ ត្រីអណ្តែងងាយស្រួលក្នុងការចិញ្ចឹមព្រោះវាអាចរស់ក្នុងមជ្ឈដ្ឋានទឹកដែលមានកម្រិតអុកស៊ីសែនរលាយក្នុងទឹកទាប ធន់ក្នុងការរស់នៅកន្លែងចង្អៀត និងចូលចិត្តរស់នៅក្នុងជម្រៅទឹកចន្លោះពី ០.៨-១ម៉ែត្រ។ ជាប្រភេទត្រីស៊ីចំណីចម្រុះក្នុងធម្មជាតិ កូនសត្វល្អិតតូចៗ កំពឹស កូនត្រី កូនក្អុក កូនកង្កែប ខ្យង លាមកសត្វ។ ក្រៅពីចំណីផ្សំសម្រេចពីរោងចក្រ ត្រីអណ្តែងអាចស៊ីកន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ សំណល់ពីទីសត្តឃាដ ចកអាសូឡា ។ល។ ចិញ្ចឹមរយៈពេលខ្លីពី ៣-៤ខែ ត្រីអាចមានទម្ងន់ចន្លោះពី ២-៤ខាំក្នុង១ក្បាល។



## ៣-បច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្រះ

### ៣.១. ការជ្រើសរើសទីតាំងជីកស្រះ÷

- ស្រះចិញ្ចឹមត្រីត្រូវមានប្រភពទឹកសាបគ្រប់គ្រាន់ ងាយស្រួលក្នុងការបញ្ចូលនិងបញ្ចេញទឹក
- ជ្រើសរើសទីតាំងស្ងប់ស្ងាត់
- ដីមានកម្រិតជ្រាបទឹកតិច ឬបាតស្រះជាប្រភេទដីឥដ្ឋ ឬដីកណ្តៀង (រក្សាទឹកបានយូរ)
- គ្មានសារធាតុពុលហូរចូលស្រះ
- នៅទីវាល មានពន្លឺថ្ងៃគ្រប់គ្រាន់ (គ្មានដើមឈើធំៗនៅជុំវិញ)
- ស្រះគួរមានផ្ទៃទឹកជាង ១០០ម៉ែត្រការ៉េ មានជម្រៅពី ១,៥-២.៥ ម៉ែត្រ និងមានមាត់ស្រះរឹងមាំ

### ៣.២. ការរៀបចំស្រះ÷

- សម្រាប់ស្រះចាស់ក្រោយពីបូមទឹកពង្រីងអស់រួចត្រូវប្រមូលកាកសំណល់ផ្សេងៗដែលមាននៅក្នុងស្រះចេញ ដូចជា កំណាត់ឈើ ថង់ផ្លាស្ទិច និងសំរាមផ្សេងៗ។
- ធ្វើការកម្ចាត់សត្វចង្រៃដូចជា កង្កែប ក្តាម ពស់ និងត្រី ដែលស៊ីសាច់ជាអាហារ
- កាប់ឆ្ការព្រៃ និងស្មៅនៅតាមមាត់ស្រះ
- ជួសជុលរៀបចំមាត់ស្រះ ស្តារភក់ទុកត្រឹមតែ ៥-១០សង់ទីម៉ែត្រ និងពង្រាបបាតស្រះឱ្យស្មើ
- បាចកំបោរសពី ៧-១០គ.ក/១០០ម៉ែ$^{២}$ និងហាលទុករយៈពេលពី ៣-៥ថ្ងៃ ដើម្បីកម្ចាត់សត្វចង្រៃ និងមេរោគដែលមាននៅក្នុងស្រះ។
- ហ៊ុំស្បៃជុំវិញស្រះ ដើម្បីការពារត្រីព្រៃ និងសត្វចង្រៃខាងក្រៅចូល និងត្រីខាងក្នុងចេញពីស្រះ
- បញ្ចូលទឹកក្នុងស្រះ ជម្រៅទឹកពី ១.២ -១.៥ម៉ែត្រ



### ៣.៣. ការដាក់កូនត្រីពូជ÷

❖ **ការជ្រើសរើសកូនត្រីពូជ÷** ការចិញ្ចឹមត្រីឱ្យទទួលបានជោគជ័យ និងបានទិន្នផលខ្ពស់ គុណភាពកូនត្រីពូជគឺជាកត្តាសំខាន់ ដោយកូនត្រីត្រូវមានទំហំប្រហាក់ប្រហែលគ្នា មានសុខភាពល្អ រហ័សរហួន មាំមួន ពណ៌ស្រស់ថ្លា គ្មានរបួសស្នាមឬដំបៅ និងគ្មានជម្ងឺ។ ទំហំកូនត្រីដែលសមស្រប សម្រាប់ដាក់ចិញ្ចឹមគឺចន្លោះពី ៥-៨សង់ទីម៉ែត្រ/ក្បាល ឬ៣០០-៥០០ក្បាល/គ.ក។

❖ **ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹម÷** ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រះគឺអាស្រ័យទៅលើសមត្ថភាពផ្ទុករបស់ស្រះ គុណភាពទឹក និងសមត្ថភាពផ្គត់ផ្គង់ចំណី។ សម្រាប់ត្រីអណ្ដែង សមត្ថភាពផ្ទុករបស់ស្រះចន្លោះពី ២ -៣.៥គ.ក/ម៉ែ៣។ ដង់ស៊ីតេដាក់កូនត្រីពូជចិញ្ចឹមគឺផ្អែកទៅលើទម្ងន់កូនត្រីពេលប្រមូលផលដែលស្របតាមតម្រូវការទីផ្សារ។ ប្រសិនបើតម្រូវការទីផ្សារ ០.២គ.ក/ក្បាល ឬ៥ក្បាល/គ.ក និងសមត្ថភាពផ្ទុករបស់ស្រះ២គ.ក/ម៉ែ៣ នោះដង់ស៊ីតេដាក់កូនត្រីពូជចិញ្ចឹមគឺ ១០ក្បាល/ម៉ែ៣។

❖ **ការលែងកូនត្រី÷** ពេលវេលាលែងកូនត្រីប្រសើរបំផុតគឺនៅពេលមេឃត្រជាក់ ដោយដាក់ថង់ផ្ទុកកូនត្រីទៅក្នុងទឹកស្រះរយៈពេលពី២០-៣០នាទី ដើម្បីឱ្យត្រីស៊ាំបន្តិចម្ដងៗនឹងសីតុណ្ហភាពនៃមជ្ឈដ្ឋានទឹកក្នុងស្រះ បន្ទាប់មកលែងកូនត្រីបន្តិចម្ដងៗចូលទៅក្នុងស្រះ។



### ៣.៤. ការផ្ដល់ចំណី÷

- ចំណីធម្មជាតិ÷ ពពួកបង្កងតុង បាក់តេរី កណ្ដៀរ និងសត្វល្អិត...
- ចំណីផ្សំចេញពីវត្ថុធាតុដើមមួយចំនួនដូចជា÷ កន្ទក់ ចុងអង្ករ ពោត សណ្ដែកសៀង កូនត្រីក្ដាម ខ្យង ខ្ចៅ កំពិស ត្រកួន បន្លែបៃតង កាកសំណល់ផ្ទះបាយ សំណល់ពីសត្តឃាដ...។

- ចំណីគ្រាប់ផលិតពីរោងចក្រ ដែលមានកម្រិតប្រូតេអ៊ីនច្បាស់លាស់ មិនសូវប៉ះពាល់ដល់គុណភាពទឹក ត្រីធំធាត់លឿន ប៉ុន្តែមានតម្លៃខ្ពស់។






| ចំណីគ្រាប់/ចំណីរោងចក្រ | ចំណីផ្សំដោយខ្លួនឯង | ចំណីធម្មជាតិបន្ថែម |
| --- | --- | --- |

**ការផ្តល់ចំណី÷** ការកំណត់នូវបរិមាណចំណី កម្រិតប្រូតេអ៊ីនក្នុងចំណី និងទំហំចំណីគឺជាកត្តាសំខាន់ដើម្បីឱ្យត្រីធំធាត់ និងទទួលបានទិន្នផលតាមផែនការកំណត់។ ចំណីដែលត្រូវផ្តល់ឱ្យត្រីស៊ីប្រចាំថ្ងៃត្រូវមានការសិក្សា និងគណនាច្បាស់លាស់។ របៀបនៃការផ្តល់ចំណី និងការគណនាចំណីត្រូវផ្តល់ប្រចាំថ្ងៃ (ចំណីគ្រាប់/ចំណីរោងចក្រ) រួមមានដូចខាងក្រោម÷

- **ចំណីគ្រាប់/ចំណីរោងចក្រ÷** ពេលត្រីនៅតូចផ្តល់ចំណី ៥.៣% នៃទម្ងន់ខ្លួនត្រី និងពេលត្រីកាន់តែធំបរិមាណចំណីកាត់បន្ថយបន្តិចម្តងៗមកត្រឹម ១.២%នៃទម្ងន់ដងខ្លួន។
- **ចំណីផ្សំដោយខ្លួនឯង(ចំណីសើម)÷** ពេលត្រីនៅតូចផ្តល់ ៩%នៃទម្ងន់ខ្លួនត្រី និងពេលត្រីកាន់តែធំបន្ថយចុះបន្តិចម្តងមកត្រឹម ៤% នៃទម្ងន់ខ្លួនត្រី។

### ៣.៥.ការគ្រប់គ្រង និងការថែទាំ÷

ក្រោយពីការលែងកូនត្រីដាក់ចិញ្ចឹមរួចមកកសិករត្រូវអនុវត្តន៍ដូចខាងក្រោម ÷

- ពិនិត្យមើលសកម្មភាពចាប់ចំណីរបស់ត្រីជារៀងរាល់ថ្ងៃ
- ពិនិត្យភ្លឺស្រះ ឬស្បៃជុំវិញស្រះ ការពារការបាក់ ឬដាច់រហែកស្បៃ
- ពិនិត្យគុណភាពទឹកស្រះឱ្យបានទៀងទាត់អំពីកម្រិតpH អុកស៊ីសែនក្នុងទឹក ដើម្បីរក្សាគុណភាពទឹកឱ្យល្អជាប្រចាំ។
- ផ្តល់ចំណីត្រីឱ្យបានគ្រប់គ្រាន់ និងទៀងទាត់ ជៀសវាងកុំឱ្យចំណីលើសច្រើន ដែលបង្កឱ្យទឹកស្រះខូចគុណភាព ហើយបង្កបញ្ហាឱ្យត្រីកើតជំងឺបាន។
- រក្សាជម្រៅទឹកនៅក្នុងស្រះយ៉ាងហោចណាស់ ១ម៉ែត្រ ទឹកមានពណ៌ត្នោតខ្ចី ឬបៃតងខ្ចី សមស្របចំពោះការចិញ្ចឹមត្រី។ នៅបណ្តាខែដែលមានសីតុណ្ហភាពខ្ពស់ ស្ទុះស្ទាប់អួសបន្ទាយពេលត្រូវបន្ថែមទឹក១ខែម្តង ពី ១៥%-២០% នៃបរិមាណទឹកក្នុងស្រះឬបញ្ចេញចោល ១/៣ នៃបរិមាណទឹកក្នុងស្រះរួចបូមទឹកថ្មីចូលវិញ។

- តាមដានសភាពប្រែប្រួលរបស់ហ្វូងត្រីដូចជា ការស៊ីចំណីខ្លាំងឬខ្សោយ ហែលតាមហ្វូងឬហែលដាច់ពីហ្វូង ពណ៌សម្បុររបស់ត្រីនៅធម្មតាដូចលក្ខណៈដើម ឬប្រែពណ៌។





## ៣.៦. ការប្រមូលផល÷

ចិញ្ចឹមរយៈពេល ៣-៤ខែ ត្រីអណ្តែងមានទម្ងន់ចន្លោះពី ០.២-០.៣គីឡូក្រាម/ក្បាល ដែលកសិករអាចចាប់ផ្តើមប្រមូលផល។ ការប្រមូលផលរំលស់ គួរចាប់ផ្តើមបន្ទាប់ពីចិញ្ចឹមបានរយៈពេលពី ២-៣ខែ ជាបណ្តើរៗ ដោយចាប់រំលស់នូវរាល់ត្រីដែលមានទំហំធំស្របតាមតម្រូវការទីផ្សារ ហើយរក្សាទុកចិញ្ចឹមបន្តត្រីដែលមានទំហំតូចៗដើម្បីឱ្យត្រីមានការលូតលាស់ធំលឿនជាងមុន ដោយកម្រិតផ្ទុករបស់ស្រះមានលក្ខណៈទូលាយជាងមុន។ ពេលប្រមូលផលត្រូវធ្វើឡើងនៅពេលមេឃត្រជាក់ ដោយកសិករត្រូវផ្អាកផ្តល់ចំណីត្រី ពី១-២ថ្ងៃមុន ដើម្បីកុំឱ្យត្រីពុលខ្សោយប៉ះពាល់ដល់គុណភាពសាច់ត្រី។ ប្រមូលផលដំណាក់កាលដំបូង កសិករត្រូវបូមទឹកចេញពីស្រះប្រមាណពី ៣០-៥០% បន្ទាប់មកប្រើអួនអូសចាប់ត្រី ២-៣ដង ឬរហូតដល់ត្រីនៅក្នុងស្រះនៅសល់ត្រឹម ១០-២០% ទើបបូមពង្រីកទឹកចាប់ត្រីសម្រេចតែម្តង។






## ៤-គម្រោងអាជីវកម្មចិញ្ចឹមត្រីអណ្តែងក្នុងស្រះ ÷

**៤-១-គម្រោងចិញ្ចឹម÷** គម្រោងចំណាយខាងក្រោមនេះគឺជាបទពិសោធន៍របស់កសិករចិញ្ចឹមត្រីអណ្តែងនៅខេត្តបាត់ដំបង។

- ទំហំស្រះ ÷ ៣,០០០ម៉ែ៣ (បណ្តោយ ៥០ម៉ែ ទទឹង ៣០ម៉ែ ជម្រៅទឹក ២ម៉ែ)
- សមត្ថភាពផ្ទុករបស់ស្រះ ÷ ២.៥គ.ក/ម៉ែ៣ ទម្ងន់កូនត្រីពេលប្រមូលផលជាមធ្យម ២៥០ក្រាម/ក្បាល ។
- ចំនួនកូនត្រីពូជ/វគ្គ ÷ ៤១,៤០០កូន (ដង់ស៊ីតេដាក់ចិញ្ចឹម ១២ក្បាល/ម៉ែ៣ និងបូកបន្ថែម ១៥% ដើម្បីគ្រប់គ្រងអត្រាបាត់បង់)។
- កូនត្រីពូជ ÷ ទិញពីកសិដ្ឋានផលិតកូនត្រីពូជមានតម្លៃ ១០០៛/ក្បាល (តម្លៃអាចប្រែប្រួលទៅតាមទំហំកូនត្រី និងការដឹកជញ្ជូន) ។
- រយៈពេលចិញ្ចឹម ÷ ៤ខែ/វគ្គ ឬអាចចិញ្ចឹមបាន ៣វគ្គ/ឆ្នាំ
- ចំណីផ្តល់ឱ្យត្រីស៊ី ÷ ចំណីគ្រាប់ក្រុមហ៊ុន ប្រូតេអ៊ីនពី ៤០%(ពេលត្រីនៅតូច) និងក្រោយចិញ្ចឹមបាន ២សប្តាហ៍ ផ្តល់ចំណីផ្សំខ្លួនឯង សំណល់ពីទីសត្តឃាត បន្លែបៃតង ចកអាសូឡា... ។
- សមាមាត្រចំណី (FCR) ÷ ជាមធ្យម ២.៤៦ (តម្លៃនេះអាចប្រែប្រួល អាស្រ័យលើការគ្រប់គ្រង និងការប្រើប្រាស់ចំណី)។
- អត្រាបាត់បង់ ÷ ជាមធ្យម ១៥% (អាស្រ័យលើសុខភាពកូនពូជ និងការថែទាំ)
- ទិន្នផល ÷ ជាមធ្យម ៩,០០០គ.ក/វគ្គ
- ទីផ្សារ ÷ លក់បោះដុំទៅឈ្មួញកណ្តាល ឬស្តង់ប្រមូលទិញត្រី
- តម្លៃទីផ្សារ ÷ ជាមធ្យម ៤,៣០០៛/គ.ក អាស្រ័យលើរដូវកាល ដែលជាទូទៅមានតម្លៃថ្លៃនៅចន្លោះខែ ឧសភា ដល់ កក្កដា ។
- តម្រូវការទុន ÷ សម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង ដោយរៀបចំជីកស្រះចិញ្ចឹម និងបំពាក់សម្ភារៈ (មិនរាប់បញ្ចូលថ្លៃដី) ត្រូវចំណាយដើមទុនប្រមាណ **៤៧,៦៤៥,០០០រៀល** ក្នុងនោះ÷

| ទុនវិនិយោគសម្រាប់ជីកស្រះ និងបំពាក់សម្ភារៈ (រៀល) | ទុនសម្រាប់ដំណើរការចិញ្ចឹមត្រីអណ្តែង (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|
| **23,110,000** | **24,535,000** | **47,645,000** |

## ៤-២-ចំណាយលម្អិតលើការចាប់ផ្ដើមអាជីវកម្មដំបូង÷

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| **ចំណាយសរុប ក+ខ** | | | | | **47,645,000** |
| **ក-ការចំណាយប្រែប្រួល** | | | | | **24,535,000** |
| 1 | កូនត្រីពូជ (បូក១៥%) | ក្បាល | 41,400 | 100 | 4,140,000 |
| 2 | កំបោរស | គ.ក | 100 | 1,500 | 150,000 |
| 3 | ចំណីសម្រេចរោងចក្រ | គ.ក | 250 | 3,700 | 925,000 |
| 4 | ចំណីផ្សំខ្លួនឯង | គ.ក | 17,460 | 1,000 | 17,460,000 |
| 5 | ប្រេងសាំងឬម៉ាស៊ូត/វគ្គ | ខែ | 4 | 40,000 | 160,000 |
| 6 | ថ្នាំការពារ និងព្យាបាល (១វគ្គ) | វគ្គ | 1 | 100,000 | 100,000 |
| 7 | កម្លាំងពលកម្ម/វគ្គ(២០%នៃកសិដ្ឋាន) | ខែ | 4 | 400,000 | 1,600,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **23,110,000** |
| 1 | ជីកស្រះ (៥០ម x៣០ម x ២.៥ម) | ម៣ | 3750 | 5,000 | 18,750,000 |
| 2 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 1,200,000 | 1,200,000 |
| 3 | ម៉ាស៊ីនកិនចំណីត្រី | គ្រឿង | 1 | 1,200,000 | 1,200,000 |
| 4 | ទុយោបូមទឹក ទន់ (៥០ម/ ដុំ) | ដុំ | 4 | 60,000 | 240,000 |
| 5 | ស្បៃហ៊ុំស្រះ និងបង្គោលឈើ | ដុំ | 8 | 50,000 | 400,000 |
| 6 | រៀបចំតង់ដាំចកអាសូឡា | កន្លែង | 1 | 300,000 | 300,000 |
| 7 | រៀបចំកន្លែងដាក់ចំណី | កន្លែង | 1 | 150,000 | 150,000 |
| 8 | សំណាញ់បង់ត្រី | វង់ | 1 | 150,000 | 150,000 |
| 9 | ជញ្ជីងថ្លឹង( អេឡិចត្រូនិច និងប៉ុង) | គ្រឿង | 2 | 260,000 | 520,000 |
| 10 | តាកាដាក់ត្រី ចានដែក ធុង... | ឈុត | 1 | 200,000 | 200,000 |

## ៤-៣-ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹមត្រីអណ្ដែង ក្នុង១វគ្គ÷

ការចិញ្ចឹមត្រីអណ្ដែងក្នុងស្រះមានផ្ទៃទឹកទំហំ ៣,០០០ម៉$^{៣}$ ដាក់កូនត្រីពូជចំនួន ៤១,៤០០ក្បាល (បូកបន្ថែមអត្រាបាត់បង់១៥%) ចិញ្ចឹមរយៈពេល ០៤ខែ (ក្នុង១វគ្គ) ក្រោយកាត់រំលស់លើការចំណាយថេរ និងការចំណាយលើការចិញ្ចឹម÷

| ចំណាយសរុប (រៀល) | ចំណូលសរុប (រៀល) | ចំណេញសរុប (រៀល) |
|---|---|---|
| **25,011,167** | **38,700,000** | **13,688,833** |

-តារាងចំណូល-ចំណាយលម្អិត÷

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | ចំនួនវគ្គវិលោះ | តម្លៃសរុប/វគ្គ (រៀល) |
|---|---|---|---|---|---|---|
| **ចំណូលពីការលក់ត្រី** | | | | | | |
| 1 | ចំណូលពីការលក់ត្រី | គ.ក | 9,000 | 4,300 | | **38,700,000** |
| **ចំណាយសរុប (ក + ខ)** | | | | | | **25,011,167** |
| **ក-ការចំណាយប្រែប្រួល** | | | | | | **24,535,000** |
| 1 | កូនត្រីពូជ (បូក១៥%) | ក្បាល | 41,400 | 100 | | 4,140,000 |
| 2 | កំបោរស | គ.ក | 100 | 1,500 | | 150,000 |
| 3 | ចំណីសម្រេចរោងចក្រ | គ.ក | 250 | 3,700 | | 925,000 |
| 4 | ចំណីផ្សំខ្លួនឯង | គ.ក | 17,460 | 1,000 | | 17,460,000 |
| 5 | ប្រេងសាំងឬម៉ាស៊ូត/វគ្គ | ខែ | 4 | 40,000 | | 160,000 |
| 6 | ថ្នាំការពារ និងព្យាបាល (១វគ្គ) | វគ្គ | 1 | 100,000 | | 100,000 |
| 7 | កម្លាំងពលកម្ម/វគ្គ(២០%នៃកសិដ្ឋាន) | ខែ | 4 | 400,000 | | 1,600,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **476,167** |
| 1 | ជីកស្រះ (៥០ម x ៣០ម x ២.៥ម) | ម៣ | 3,750 | 5,000 | 120 | 156,250 |
| 2 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 1,200,000 | 20 | 60,000 |
| 3 | ក្បាលកិនចំណីត្រី | គ្រឿង | 1 | 1,200,000 | 20 | 60,000 |
| 4 | ទុយោបូមទឹកទន់ (៥០ម/ ដុំ) | ដុំ | 4 | 60,000 | 20 | 12,000 |
| 5 | ស្បៃហ៊ុំស្រះ និងបង្គោលឈើ | ដុំ | 8 | 50,000 | 8 | 50,000 |
| 6 | រៀបចំតង់ដាំចកអាសូឡា | កន្លែង | 1 | 300,000 | 12 | 25,000 |
| 7 | រៀបចំកន្លែងដាក់ចំណី | កន្លែង | 1 | 150,000 | 12 | 12,500 |
| 8 | សំណាញ់បង់ត្រី | វង់ | 1 | 150,000 | 8 | 18,750 |
| 9 | ជញ្ជីងថ្លឹង(អេឡិចត្រូនិច និងប៉ុង) | គ្រឿង | 2 | 260,000 | 8 | 65,000 |
| 10 | តាកាដាក់ត្រី ចានដែក ធុង... | ឈុត | 1 | 200,000 | 12 | 16,667 |
| ចំណេញសរុប | | | | | | **13,688,833** |
| ចំណាយថ្លៃដើមក្នុងការចិញ្ចឹមត្រីក្នុង១ គ.ក | | | | | | **2,779** |
| ចំណេញពីការផលិតត្រីសាច់ ១ គ.ក | | | | | | **1,521** |

### ៤-៤-ការវិភាគលទ្ធផលដោយផ្អែកលើអត្រាបាត់បង់ និងតម្លៃលក់÷

តាមរយៈក្រុមការងារបានសិក្សាផ្ទាល់នៅកសិដ្ឋានចិញ្ចឹមត្រីអណ្ដែងនៅខេត្តបាត់ដំបង ឃើញថា ការចិញ្ចឹមត្រីអណ្ដែងក្នុងស្រះមានអត្រាបាត់បង់១០-២០% តម្លៃលក់បោះដុំជាមធ្យម ៤,៣០០៛/គ.ក និងត្រីមានទម្ងន់ជាមធ្យម ០.២៥គ.ក/ក្បាល ÷

***-តារាងវិភាគលទ្ធផលផ្អែកលើអត្រាបាត់បង់ និងតម្លៃលក់***

| ទិន្នផលទទួលបាន (គ.ក) | តម្លៃលក់ចេញ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពី ទិន្នផល |
|---|---|---|---|---|---|
| 9,315 | 3,800 | 35,397,000 | 25,011,167 | 10,385,833 | ករណីអត្រាបាត់បង់១០% និងទម្ងន់ត្រឹមធ្យម ០.២៥គ.កក្នុង១ក្បាល |
| | 4,300 | 40,054,500 | 25,011,167 | 15,043,333 | |
| | 5,000 | 46,575,000 | 25,011,167 | 21,563,833 | |
| | 5,500 | 51,232,500 | 25,011,167 | 26,221,333 | |
| 9,000 | 3,800 | 34,200,000 | 25,011,167 | 9,188,833 | ករណីអត្រាបាត់បង់១៥% និងទម្ងន់ត្រឹមធ្យម ០.២៥គ.កក្នុង១ក្បាល |
| | 4,300 | 38,700,000 | 25,011,167 | 13,688,833 | |
| | 5,000 | 45,000,000 | 25,011,167 | 19,988,833 | |
| | 5,500 | 49,500,000 | 25,011,167 | 24,488,833 | |
| 8,280 | 3,800 | 31,464,000 | 25,011,167 | 6,452,833 | ករណីអត្រាបាត់បង់២០% និងទម្ងន់ត្រឹមធ្យម ០.២៥គ.កក្នុង១ក្បាល |
| | 4,300 | 35,604,000 | 25,011,167 | 10,592,833 | |
| | 5,000 | 41,400,000 | 25,011,167 | 16,388,833 | |
| | 5,500 | 45,540,000 | 25,011,167 | 20,528,833 | |

**ចំណាំ÷** ក្នុងករណីកូនត្រីពូជមានសុខភាពមិនល្អ ការគ្រប់គ្រង និងថែទាំមិនបានត្រឹមត្រូវ ឬមានបញ្ហាជាយថាហេតុណាមួយកើតឡើង នាំឱ្យអត្រាបាត់បង់ឡើងដល់ ២០% នឹងប៉ះពាល់ដល់ទិន្នផលត្រីសរុប និងផលចំណេញរបស់កសិករ។ ករណីអត្រាបាត់បង់ ២០% ទម្ងន់ត្រឹមធ្យម ០.២៥គ.ក/ក្បាល ទម្ងន់ត្រីប្រមូលផលបានចំនួន ៨,២៨០គ.ក។ បើតម្លៃលក់បាន ៣,៨០០៛/គ.ក ចំណូលសរុប ៣១,៤៦៤,០០០៛ និងក្រោយកាត់ការចំណាយ កសិករបានចំណេញបានប្រមាណ ៦៤៥២,៨៣៣៛/វគ្គ។

### ៤-៥-ខ្សែច្រវាក់តម្លៃ÷

**កសិករ** ÷ ករណីលក់បោះដុំបានតម្លៃ ៤,៣០០៛/គ.ក តម្លៃថ្លៃដើមផលិត ២,៧៧៩៛/គ.ក អាចចំណេញបាន ១,៥២១៛/គ.ក ។

**ឈ្មួញកណ្ដាល**÷ លក់បោះដុំបន្តតម្លៃ ៦,៥០០៛/គ.ក កាត់ថ្លៃដឹកជញ្ជូន លើកដាក់ ៥០០៛/គ.ក អាចចំណេញបាន ១,៧០០៛/គ.ក ។

**អ្នកលក់រាយ** ÷ លក់តម្លៃ ១០,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថៃរក្សា ១,០០០៛/គ.ក អាចចំណេញបាន ២,៥០០៛/គ.ក ។

## ៥-ហានិភ័យ និងបញ្ហាប្រឈម

កសិករដែលមានបំណងចិញ្ចឹមត្រីអណ្តែងក្នុងស្រះ ត្រូវស្វែងយល់ និងរកវិធីគ្រប់គ្រងនូវហានិភ័យ និងបញ្ហាប្រឈមចម្បងៗមួយចំនួនទៅលើអាជីវកម្ម រួមមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាហានិភ័យ | វិធានការក្នុងការគ្រប់គ្រងហានិភ័យ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ទិន្នផលដែលទទួលបានទាបជាងការរំពឹងទុក មកពីការរៀបចំស្រះចិញ្ចឹមមិនត្រឹមត្រូវ ប្រឈមនឹងការបាត់បង់កូនត្រី កក្តាសត្វចង្រៃ និងត្រីព្រៃពីខាងក្រៅចូលស៊ីកូនត្រី ។ | - សម្អាតកាកសំណល់ និងប្រភេទត្រីកាចដែលមាននៅក្នុងស្រះឱ្យបានត្រឹមត្រូវ។<br>- ប្រើបរិមាណកំបោរសស្របតាមការណែនាំ<br>- យកចិត្តទុកដាក់ក្នុងការរៀបចំស្រះ និងប្រើស្បៃហ៊ុំការពារជុំវិញស្រះ។ |
| | | ទិញពូជត្រីមិនល្អ សុខភាពខ្សោយ និង ទំហំកូនត្រីមិនស្មើគ្នា ទទួលបានទិន្នផលទាបជាងការរំពឹងទុក។ | - សិក្សាប្រវត្តិកសិដ្ឋានផលិតកូនត្រីឱ្យបានច្បាស់លាស់អំពីមេពូជ។<br>- ត្រូវជ្រើសរើសកូនត្រីមានទំហំប៉ុនៗគ្នាដើម្បីកាត់បន្ថយត្រីធំស៊ីត្រីតូច។<br>- ជ្រើសរើសកូនត្រីពូជមានសុខភាពល្អ មិនមានជំងឺ និងរបួសស្នាមលើដងខ្លួន។<br>- តាមដានតាំងពីចាប់ផ្តើមផលិតដំបូងរហូតដល់ថ្ងៃទទួលកូនត្រីមកចិញ្ចឹម។ |
| | | គុណភាពទឹកមិនល្អ កើតមានជាតិពុល ខ្វះអុកស៊ីសែនក្នុងទឹក នាំឱ្យកូនត្រីពុលទឹក កើតមានជំងឺ និងត្រីងាប់។ | - ពិនិត្យគុណភាពទឹកឱ្យបានទៀងទាត់លើកម្រិតប៉េហាស់ កម្រិតថ្លា និងអុកស៊ីសែន។<br>- ប្តូរទឹកពី ១៥-២០% មួយខែម្តង<br>- តាមដានសកម្មភាពត្រីពេលផ្តល់ចំណី |
| ២ | ហានិភ័យទីផ្សារ | ទាក់ទងទៅនឹងការបាត់បង់ទីផ្សារឬតម្លៃដែលទទួលបានទាបជាងការរំពឹងទុក។ តម្លៃទីផ្សារត្រីសាច់ប្រែប្រួលមិនច្បាស់លាស់។ | - ស្វែងរកទីផ្សារឬឈ្មួញប្រមូលទិញឱ្យបានច្រើនកន្លែង។<br>- ទម្ងន់ត្រឹមធ្យមសមស្របតាមតម្រូវការទីផ្សារ ចងក្រងជាបណ្តុំអ្នកចិញ្ចឹមត្រីដើម្បីភ្ជាប់ខ្សែច្រវាក់តម្លៃទីផ្សារ។ |
| | | តម្លៃចំណីត្រី និងវត្ថុធាតុដើមក្នុងការផលិតចំណីផ្សំកើនឡើង នាំឱ្យថ្លៃដើមផលិតខ្ពស់ | រកវត្ថុធាតុដើមក្នុងតំបន់មានតម្លៃទាបសម្រាប់ផលិតចំណីផ្សំ ដើម្បីកាត់បន្ថយថ្លៃដើមផលិតឱ្យមានកម្រិតទាបសមរម្យ ដើម្បីមានលទ្ធភាពក្នុងការប្រកួតប្រជែង។ |

## ៦-សេចក្តីសន្និដ្ឋាន

ត្រីអណ្តែងជាប្រភេទត្រីដែលមានតម្រូវការទីផ្សារខ្ពស់ ប៉ុន្តែតម្លៃមានការប្រែប្រួលមិនទៀតទាត់ ដោយសារមានការប្រកួតប្រជែងជាមួយនិងត្រីនាំចូលពីប្រទេសជិតខាង។ ជាមួយនឹងថ្លៃដើមផលិត ២,៧៧៩៛/គ.ក បើសិនជាលក់បោះដុំបានតម្លៃជាមធ្យម ៤,៣០០៛/គ.ក កសិករទទួលបានផលចំណេញ ១,៥២១៛/គ.ក។ ត្រីអណ្តែងមិនសូវជាលំបាកក្នុងការចិញ្ចឹម និងមានតម្លៃទីផ្សារល្អសម្រាប់លក់រាយក្នុងតំបន់។ ប៉ុន្តែបើសិនជាចិញ្ចឹមជាលក្ខណៈអាជីវកម្មទ្រង់ទ្រាយធំ កសិករតែងជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា÷ ត្រីកើតមានជំងឺច្រើន អត្រាបាត់បង់ខ្ពស់ ថ្លៃដើមផលិតខ្ពស់ តម្លៃលក់ដុំប្រែប្រួលមិនទៀងទាត់ ដែលនាំឱ្យកសិករអាចទទួលបានផលចំណេញតិចឬខាតបង់ករណីបើតម្លៃលក់ធ្លាក់ចុះខ្លាំង។ ដូចនេះកសិករត្រូវមានផែនការផលិតច្បាស់លាស់ និងត្រូវចេះកែច្នៃចំណីផ្សំបន្ថែម ដើម្បីចូលរួមកាត់បន្ថយថ្លៃដើមផលិត។

### ប្រភពទីកន្លែង និងឯកសារសម្រាប់សិក្សាស្រាវជ្រាវ÷

១- កសិដ្ឋានចិញ្ចឹមត្រីអណ្តែងក្នុងស្រះ នៅខេត្តបាត់ដំបង

២-ឯកសារបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងអាង តង់ប្លាស្ទិក និងឯកសារចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

-បណ្ណាល័យកសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ÷ *https://elibrary.maff.gov.kh/*

៣- បច្ចេកទេសចិញ្ចឹមត្រីអណ្តែងនៅក្នុងគេហទំព័រ Facebook និង YouTube រួមមាន÷

- *https://fundservice.blogspot.com/2016/10/blog-post_50.html*
- *https://www.youtube.com/watch?app=desktop&v=lmzcw-eIgzc*
- *https://www.youtube.com/watch?v=vrcFwuFa0SU*
- *https://www.popular.com.kh/pop-biz/205985.html/*